# និន្នាការសេដ្ឋកិច្ចសង្គម

# Socio-Economic Trends

**ខែមីនា - មេសា ឆ្នាំ២០១៧**

**March - April 2017**

## មាតិកា


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប / Executive summary** | **២** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia economic trends** | **៥** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index | ៥ |
| ១.២. វិស័យហិរញ្ញវត្ថុ / Finance | ៦ |
| ១.៣. វិស័យពាណិជ្ជកម្ម / Trade | ៧ |
| ១.៤. ការអនុវត្តថវិកា / Budget execution | ៨ |
| ១.៥. វិស័យវិនិយោគឯកជន / Private investment | ៩ |
| ១.៦. វិស័យទេសចរណ៍ / Tourism | ១០ |
| ១.៧. វិស័យសំណង់ / Construction | ១០ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ / International commodity prices** | **១១** |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) | ១១ |
| ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ១១ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) | ១១ |
| **៣. ឧបសម្ព័ន្ធ** | **១៣** |

# ខ្លឹមសារសង្ខេប

១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែមីនា ឆ្នាំ២០១៧ ពុំមានការកើនឡើងទេធៀបនឹងខែកន្លងទៅ។ សន្ទស្សន៍ថ្លៃនៃក្រុមទំនិញមួយចំនួនបានកើនឡើងបន្តិច ដូចជាសន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់, សន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹងបានស្ថិតនៅថេរ ក្នុងនោះថ្លៃទំនិញមួយចំនួនមានការកើនឡើងដូចជាសាច់ជ្រូក សាច់ទានិងផ្លែឈើ ប៉ុន្តែត្រូវបានផាត់ទាត់ដោយការថយចុះនៃថ្លៃទំនិញមួយចំនួនទៀតដូចជាសាច់មាន់ ត្រីស្រស់និងបន្លែ។

បើធៀបនឹង១ឆ្នាំមុន អតិផរណាមានអត្រា ៤,២% ក្នុងនោះសន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈគ្មានជាតិស្រវឹងបានកើនឡើង ៥,៦% ដោយសារកំណើនថ្លៃសាច់គោ សាច់មាន់ សាច់ជ្រូក ត្រីស្រស់និងបន្លែ។ សន្ទស្សន៍ថ្លៃការដឹកជញ្ជូនបានកើនឡើង ៦% ក្នុងនោះថ្លៃប្រេងសាំងធម្មតាកើន ១៥,៤% និងថ្លៃប្រេងម៉ាស៊ូត កើន ១២,៥%។ ក្នុងរយៈពេលបីខែដើមឆ្នាំ ២០១៧ ថ្លៃប្រេងសាំងនិងប្រេងម៉ាស៊ូតជារួមខ្ពស់ជាងក្នុងរយៈពេលដូចគ្នាឆ្នាំ២០១៦ ដែលកំណើននេះគឺស្របនឹងនិន្នាការថ្លៃប្រេងឆៅលើទីផ្សារអន្តរជាតិផងដែរដោយសារការអនុវត្តកិច្ចព្រមព្រៀងកាត់បន្ថយបរិមាណផលិតប្រេងនៃបណ្តាប្រទេសសមាជិកOPECនិងប្រទេសផលិតប្រេងមួយចំនួនទៀត។ ទន្ទឹមនឹងកំណើនអតិផរណា ជាពិសេសកំណើនថ្លៃម្ហូបអាហារ ថ្លៃកសិផលមួយចំនួនដែលលក់ចេញពីកសិដ្ឋានបានថយចុះ ដូចជាថ្លៃស្រូវ ដំឡូងមីនិងម្រេចជាដើម។

២. *ឥណទាន÷* គិតត្រឹមខែមីនា ឆ្នាំ២០១៧ ឥណទានផ្តល់ដោយធនាគារពាណិជ្ជមាន ៥៧.៨៣៤ប៊ីលានរៀល បានថយចុះ ០,៧%ធៀបនឹងខែមុន (បានកើន ១៣,៧%ធៀបនឹង១ឆ្នាំមុន), ក្នុងនោះឥណទានផ្តល់ដល់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុមាន ៤៦.៧៩៩ប៊ីលានរៀល បានថយចុះ ១,៣%ធៀបនឹងខែមុន ក្នុងនោះមានការថយចុះច្រើននូវឥណទានផ្តល់ដល់វិស័យឧស្សាហកម្មនិងសេវាកម្ម, រីឯឥណទានដល់រូបវន្តបុគ្គលនិងផ្សេងៗបានបន្តកើនឡើងក្នុងខែនេះ។

*អត្រាប្តូរប្រាក់÷* ប្រាក់រៀលបានថយចុះតម្លៃបន្តិចក្នុងខែមេសា ឆ្នាំ២០១៧, គិតត្រឹមខែមេសា អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារស្មើនឹង ៤.០៣៥រៀល/ដុល្លារ ដែលអត្រាខែមីនាស្មើ ៤.០០៥រៀល/ដុល្លារ និងអត្រាខែកុម្ភៈស្មើ ៤.០០៤រៀល/ដុល្លារ។ ធនាគារជាតិកម្ពុជាអនុវត្តរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង ដោយធ្វើអន្តរាគមលើទីផ្សារប្តូរប្រាក់ដើម្បីគ្រប់គ្រងនិងរក្សាស្ថិរភាពអត្រាប្តូរប្រាក់។

*ការផ្គត់ផ្គង់រូបិយវត្ថុ÷* គិតត្រឹមខែមីនា ឆ្នាំ២០១៧ រូបិយវត្ថុទូទៅM2មានចំនួន ៦០.៥៤៧ប៊ីលានរៀល បានកើនឡើង ១,៦%ធៀបនឹងខែមុន និងបានកើនឡើង ១៩,០%ធៀបនឹង១ឆ្នាំមុន ក្នុងនោះប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសបានកើនឡើងខ្ពស់ធៀបនឹងខែកន្លងទៅ គឺបានកើនឡើង ៣,១% និងបានកើនឡើង ១៩,៦%ធៀបនឹង១ឆ្នាំមុន។

*ផ្នែកទីផ្សារមូលបត្រ÷* នៅខែមេសា ឆ្នាំ២០១៧ សកម្មភាពជួញដូរមូលបត្របានងើបឡើងវិញបន្តិចបើធៀបនឹងដើមឆ្នាំ គឺទំហំទិញលក់លើទីផ្សារមាន ៥៦៤លានរៀល ប៉ុន្តែនៅទាបជាងក្នុងឆ្នាំ២០១៦កន្លងទៅ ដែលជាមធ្យមមានទំហំតម្លៃទិញលក់ ៨៣៥លានរៀលក្នុង១ខែ។ ក្រុមហ៊ុនកំពង់ផែស្វយ័តក្រុងព្រះសីហនុបានបញ្ចប់ការធ្វើប៊ុកបៀលឌីង និងសម្រេចបានថ្លៃ ៥.០៤០រៀលក្នុង១ភាគហ៊ុន។ លក្ខខ័ណ្ឌសំខាន់ៗចំពោះដើមទុននិងប្រាក់ចំណេញរបស់ក្រុមហ៊ុនសម្រាប់ការបោះផ្សាយមូលបត្រជាលើកដំបូង(IPO)មាន÷ ដើមទុនភាគហ៊ុនិកសរុបមិនតិចជាង ៣០ប៊ីលានរៀល, ប្រាក់ចំណេញសុទ្ធនៃឆ្នាំសារពើពន្ធចុងក្រោយមិនតិចជាង ២ប៊ីលានរៀល និងប្រាក់ចំណេញសុទ្ធនៃរយៈពេល ២ឆ្នាំសារពើពន្ធចុងក្រោយមិនតិចជាង ៣ប៊ីលានរៀល។

៣. *ការនាំចូល÷* ក្នុងខែមីនា ឆ្នាំ២០១៧ ការនាំចូលគិតជាទឹកប្រាក់សរុប ១.១៦៥លានដុល្លារ បានកើនឡើង ២២,៨% ធៀបនឹងខែមុន គាំទ្រដោយកំណើនខ្ពស់នូវការនាំចូលមុខទំនិញវាយនភ័ណ្ឌ បរិក្ខារសំណង់ គ្រឿងយន្ត និងមុខទំនិញផ្សេងៗ ប៉ុន្តែដោយឡែកការនាំចូលប្រេងឥន្ធនៈបានធ្លាក់ចុះក្នុងខែមីនានេះនិងទាបជាងក្នុងឆ្នាំកន្លងទៅ គិតជាទឹកប្រាក់ ៦៩លានដុល្លារ ដែលក្នុងឆ្នាំ២០១៦ ជាមធ្យមមានការនាំចូលប្រេងឥន្ធនៈប្រមាណ ១០៦លានដុល្លារក្នុងមួយខែ។

*ការនាំចេញ÷* ក្នុងខែមីនា ឆ្នាំ២០១៧ ការនាំចេញគិតជាទឹកប្រាក់មានចំនួន ៨៩៣លានដុល្លារ បានកើនឡើង ៧,៤% ធៀបនឹងខែកន្លងទៅ, ក្នុងនោះការនាំចេញវាយនភ័ណ្ឌនិងស្បែកជើងបានកើនឡើងមកវិញបន្ទាប់ពីបានថយចុះក្នុងខែកន្លងទៅ ការនាំចេញអង្ករបានបន្តកើនឡើង រីឯការនាំចេញកៅស៊ូបានថយចុះបន្តិចក្នុងខែមីនានេះ, ប៉ុន្តែបើធៀបនឹងខែដូចគ្នាឆ្នាំមុន ការនាំចេញកៅស៊ូនៅតែមានការកើនឡើង។

៤. ក្នុងខែមីនា ឆ្នាំ២០១៧ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណូលក្នុងប្រទេសសរុប ១.៧៨៧ប៊ីលានរៀល បានកើនឡើង ២៥,៦% ធៀបនឹងខែមុន ដោយមានកំណើនឡើងចំណូលពន្ធផ្ទាល់ ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស និងចំណូលមិនមែនសារពើពន្ធ, ការអនុវត្តចំណាយសរុប ១.៣៥៩ប៊ីលានរៀល បានកើនឡើង ២២,៩% ធៀបនឹងខែមុន ដោយមានកំណើនខ្ពស់លើចំណាយបៀវត្ស។ តុល្យភាពថវិកាចរន្តសម្រាប់ខែមីនា ឆ្នាំ២០១៧ មានអតិរេកសាច់ប្រាក់ ៨៤៦ប៊ីលានរៀល និងតុល្យភាពថវិកាសរុបមានអតិរេកសាច់ប្រាក់ ៤២៨ប៊ីលានរៀល។

ជារួមនៅត្រីមាសទី១ ឆ្នាំ២០១៧នេះ ចំណូលក្នុងប្រទេសសរុបអនុវត្តបានចំនួន ៤.២៦២ប៊ីលានរៀល គឺខ្ពស់ជាងច្បាប់ថវិកាប្រចាំឆ្នាំ ២,២% ឬបានកើនឡើង ២០,៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៦, ចំណាយរដ្ឋបាលថ្នាក់ជាតិសរុប ៣.០៩១ប៊ីលានរៀល ទាបជាងច្បាប់ថវិកាប្រចាំឆ្នាំ ៩,២% ប៉ុន្តែបានកើនឡើង ៣០,៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំកន្លងទៅ ដោយមានកំណើនចំណាយលើវិស័យការពារនិងសន្តិសុខជាតិ និងចំណាយរដ្ឋបាលស៊ីវិល។ ជារួមក្នុងត្រីមាសទី១ ឆ្នាំ២០១៧នេះ តុល្យភាពថវិកាចរន្តមានអតិរេកសាច់ប្រាក់ ១.៩៥៩ប៊ីលានរៀល និងតុល្យភាពថវិកាសរុបមានអតិរេកសាច់ប្រាក់ ១.១០០ប៊ីលានរៀល។

៥. ក្នុងរយៈពេល ០៣ខែ ឆ្នាំ២០១៧នេះ ចំនួនគម្រោងវិនិយោគអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសរុបមាន ២១គម្រោង គិតជាទុនវិនិយោគ ១៣១លានដុល្លារ បានថយចុះ ៨៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះមានការថយចុះខ្លាំងនូវវិនិយោគវិស័យកសិកម្ម សេវាកម្មនិងទេសចរណ៍។ គម្រោងវិនិយោគអនុញ្ញាតក្នុងរយៈពេល ០៣ខែឆ្នាំ២០១៧នេះ វិនិយោគទុនកម្ពុជាមាន ១៨,២% និងវិនិយោគទុនពីបណ្តាប្រទេសសំខាន់ៗមាន អង់គ្លេស ២៦,៩% ចិន(ដីគោក) ២១,៤% តំបន់តៃវ៉ាន់និងហុងកុង ១៨,២% កូរ៉េខាងត្បូង ១១,៨% និងប្រទេសផ្សេងៗទៀត ៣,៥%។

៦. ក្នុងខែកុម្ភៈ ឆ្នាំ២០១៧ ចំនួនមកដល់នៃភ្ញៀវអន្តរជាតិមាន ៤៩៣ពាន់នាក់ បានថយចុះ ៧,៣% ធៀបនឹងខែមករាកន្លងទៅ ប៉ុន្តែខ្ពស់ជាងខែដូចគ្នាឆ្នាំមុន ១០,០%។ កម្ពុជាបានមានកំណើនខ្ពស់នៃចំនួនទេសចរអន្តរជាតិ ជាមួយចំនួនមកដល់នៃភ្ញៀវអន្តរជាតិ ២លាននាក់ក្នុងឆ្នាំ២០០៧ និង ៥លាននាក់ក្នុងឆ្នាំ២០១៦។ វិស័យទេសចរណ៍ជាវិស័យចម្បងមួយក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច ក្នុងនោះការបង្កើនភាពទាក់ទាញភ្ញៀវទេសចរបង្កើនការចាយវាយដើម្បីទ្រទ្រង់ចំណូលប្រជាពលរដ្ឋជាគោលដៅសំខាន់នៃសក្តានុពលវិស័យនេះ។

៧. ក្នុងរយៈពេល៣ខែ ឆ្នាំ២០១៧នេះ សំណើសាងសង់សុរុបមាន ៧៨៦គម្រោង បានកើនឡើង ៣១៣គម្រោងធៀបនឹងខែកន្លងទៅ, ប៉ុន្តែបើគិតជាផ្ទៃក្រឡាសាងសង់មាន ២.០៧៣ពាន់ម៉ែត្រការ៉េ បានថយចុះ ៤៥,៤%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន និងគិតជាតម្លៃសាងសង់សុរុប ១.១៨២លានដុល្លារ បានថយចុះ ២២,២%។

៨. *ថ្លៃប្រេងឆៅ* ក្នុងខែមេសា ឆ្នាំ២០១៧ ថ្លៃប្រេងឆៅមានការប្រែប្រួលខ្លាំងដោយបានកើនឡើងក្នុង២សប្តាហ៍ដំបូង និងបានថយចុះមកវិញជាបន្តបន្ទាប់ក្នុង២សប្តាហ៍ចុងក្រោយនៃខែ។ គិតត្រឹមខែមេសា ប្រេងឆៅក្នុងកិច្ចសន្យាលក់១ខែខាងមុខ ប្រេងBrentថ្លៃ ៥១,៧ដុល្លារ/ធុង ប្រេងDubaiថ្លៃ ៥១,៥ដុល្លារ/ធុង និងប្រេងWTIថ្លៃ ៤៩,៣ដុល្លារ/ធុង ជារួមបានថយចុះបន្តិចធៀបនឹងខែមីនាកន្លងទៅ។ យោងតាមភ្នាក់ងារអង្កេតថ្លៃប្រេងអន្តរជាតិរបស់ប្រទេសចិន(OilSNS)ការថយចុះនៃថ្លៃប្រេងឆៅនៅចុងខែមេសា គឺបណ្តាលពីការដំណើរការផលិតកម្មឡើងវិញនៅតំបន់ផលិតប្រេងមួយចំនួននៅប្រទេសលីប៊ី និងម៉្យាងទៀតទិន្នន័យរបស់ភ្នាក់ងារថាមពលអន្តរជាតិ(IEA) បានបង្ហាញពីកំណើនខ្ពស់នៃសាំងស្តុកសហរដ្ឋអាមេរិកនៅសប្តាហ៍ទីបីក្នុងខែមេសានេះ។

*ថ្លៃអង្ករ* ក្នុងខែមេសា ឆ្នាំ២០១៧*(១)អង្ករកម្ពុជា* អង្ករនាំចេញរបស់កម្ពុជា(ខ្ទេច៥%)ថ្លៃ ៤២០ដុល្លារ/តោន បានកើនឡើង ១,២%ធៀបនឹងខែមុន និងស្មើនឹង១ឆ្នាំមុន។ *(២)អង្ករថៃ* អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៣៨៧ដុល្លារ/តោន បានកើនឡើង ៣,៥%ធៀបនឹងខែមុន ប៉ុន្តែបានថយចុះ ២,១%ធៀបនឹង១ឆ្នាំមុន។ *(៣)អង្ករវៀតណាម* អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៣៥០ដុល្លារ/តោន បានថយចុះ ០,៦%ធៀបនឹងខែមុន និងបានថយចុះ ៣,៨%ធៀបនឹង១ឆ្នាំមុន, ការថយចុះថ្លៃនេះគឺដោយសារការប្រកួតប្រជែងខ្លាំងជាមួយប្រទេសថៃនិងឥណ្ឌា និងការប្រែប្រួលអាកាសធាតុដែលបណ្តាលអោយប៉ះពាល់ដល់គុណភាពផងដែរ។

*ថ្លៃកៅស៊ូ* គិតត្រឹមខែមេសា ឆ្នាំ២០១៧ កៅស៊ូស្តង់ដារTSR20ថ្លៃ ១.៨២០ដុល្លារ/តោន បានធ្លាក់ចុះ ៨,៥% និងកៅស៊ូSGP/MYSថ្លៃ ២.២០០ដុល្លារ/តោន បានធ្លាក់ចុះ ៤,៧%ធៀបនឹងខែមីនា ឆ្នាំ២០១៧។ យោងតាមរបាយការណ៍បឋមរបស់សមាគមប្រទេសផលិតកៅស៊ូធម្មជាតិANRCP ក្នុងរយៈពេល ០៤ខែឆ្នាំ២០១៧នេះ ពិភពលោកមានកង្វះការផ្គត់ផ្គង់កៅស៊ូធម្មជាតិប្រមាណ ៤៦៦ពាន់តោន, ប៉ុន្តែទោះមានកង្វះការផ្គត់ផ្គង់ក្តី ថ្លៃកៅស៊ូបានថយចុះចាប់ពីខែកុម្ភៈមកដោយភាគច្រើនគឺបណ្តាលមកពីកត្តាខាងក្រៅ ដូចជាការថយចុះនៃថ្លៃប្រេងឆៅ ភាពបរាជ័យក្នុងការអនុវត្តកិច្ចព្រមព្រៀងបន្ថយទិន្នផលផលិតកម្មប្រេងរបស់សមាជិកOPEC និងប្រទេសផលិតប្រេងសំខាន់ៗផ្សេងទៀត។

*(ចំពោះសេចក្តីលម្អិតនៃរបាយការណ៍ សូមទាក់ទងផ្ទាល់នាយកដ្ឋានស្ថិតិ នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)*

# ៣. ឧបសម្ព័ន្ធ

## សូចនាករនាំមុខ (Leading Indicators)


















# អតិផរណានិងទុនបំរុងបរទេស (Inflation and Foreign Reserves)




Source: NBC




Source: NIS




Source: NIS




Source: NIS




Source: NIS




Source: NBC

# អត្រាប្តូរប្រាក់ (Exchange Rate)

**Exchange rate R/100Đ and R/B**




Source: IMF

**Exchang Rate Mal-Ringgit/$ and Phi-Peso/$**




Source: IMF

**CPI and Exchange rate R/$**




Source: IMF

**Exchange rate EU Euro/US$ and Pound/US$**




Source: IMF

**Exchange rate Aus-$ and HK-$**




Source: IMF

**Exchange rate Sing-$ and Yen-$**




Source: IMF

# វិស័យរូបិយវត្ថុ និងធនាគារ (Money and Banking)


















# ការអនុវត្តថវិការ (Budget)

ចំណូលក្នុងប្រទេស និង ពន្ធលើពាណិជ្ជកម្ម ឆ្នាំ ២០១៦-២០១៧




ចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ឆ្នាំ២០១៦-២០១៧




ចំណាយចរន្ត និង វិនិយោគឆ្នាំ ២០១៦-២០១៧




ការដកសាច់ប្រាក់កម្ចីទ្វេភាគី និងពហុភាគី ឆ្នាំ ២០១៦-២០១៧




ចំណាយបៀវត្ស និង មិនមែនបៀវត្ស ឆ្នាំ ២០១៦-២០១៧




Source: MEF

ចំណាយការពារសន្តិសុខ និង រដ្ឋបាលស៊ីវិលឆ្នាំ ២០១៦-២០១៧



# វិនិយោគឯកជន និង ការបង្កើតការងារ (Investment and Employment)

**CDC Approval, Fixed Assets and Growth (Mn. $)**




Source: CDC

**CDC Approvals- Fixed Assets by Sectors (Mn. $)**




Source: CDC

**Number of Jobs ('000 person)**




Source: CDC

**Public Investment by Source of Finance (Bn.R)**




Source: MEF

**Net Loans Disbursement (Bn.R)**




Source: MEF

**CDC Approvals, Fixed assets by Sources (Mn. $)**




Source: CDC

# សំយោគពាណិជ្ជកម្ម (Trades)

### Import and Export (mil.US$)




Source: Customs and Excise Department

### Import and Export Growth




Source: Customs and Excise Department

### Trade Balance and CA as % GDP




Source: National Bank of Cambodia, NBC, and Customs Dept.

### Export by Main Continents (mil.US$)




Souce: Customs and Excise Department, MEF
(including foreign currency exports )

### Export by Commodity Group ( in tonnes)




Souce: Customs and Excise Department, MEF

### Export Clothing and Rubber (mil.US$)




Souce: Customs and Excise Department, MEF

********

***រៀបចំដោយ***

***អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ***

***ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ***

*ព័ត៌មានផ្សេងៗ សូមទាក់ទង*

*ទូរស័ព្ទលេខ៖ ០២៣ ៤២៧៩១៣, ០៧៧ ៧០៣៤៣៦, ០៩៦ ៩៧៩១៦៨៦*

*ម៉ោងធ្វើការ៖ ៧:០០ ដល់ ១១:០០ ព្រឹក និង ២:០០ ដល់ ៥:០០ រសៀល*